# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ ១២៨ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការបង្កើតអង្គភាពគ្រប់គ្រងគំរោងកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ / នស /៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៦០២ / ១៩៨ ចុះថ្ងៃទី ១៩ ខែមិថុនា ឆ្នាំ ២០០២ ស្តីពីការបង្កើតក្រុមប្រឹក្សាកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

-បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ.បក ចុះថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០០២ ស្តីពីការបង្កើតអង្គភាពសំរបសំរួលអចិន្ត្រៃយ៍ នៃក្រុមប្រឹក្សាកំណែទំរង់ច្បាប់ និងបព័ន្ធ យុត្តិធម៌

-បានឃើញអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០០២ ស្តីពីភារកិច្ច និងបេសកកម្មរបស់ក្រុមប្រឹក្សាកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

-យោងតាមសំណើរបស់សហប្រធានក្រុមប្រឹក្សាកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

## សំរេច

**មាត្រា ១.-**

ត្រូវបានបង្កើតអង្គភាពគ្រប់គ្រងគំរោងកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដើម្បីជួយអង្គភាពសំរបសំរួលអចិន្ត្រៃយ៍ ( អ.ស.អ) ក្នុងការបំពេញតួនាទី ជាសេនាធិការ នៃក្រុមប្រឹក្សាកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ( ក.ក.ច.យ) ។

៨១

**មាត្រា ២.-**

អង្គភាពគ្រប់គ្រងគំរោងកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ មានភារកិច្ច ដូចតទៅ :

-គ្រប់គ្រងកិច្ចការរដ្ឋបាលទូទៅ និងកិច្ចការហិរញ្ញវត្ថុ របស់គំរោងកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

-ទំនាក់ទំនងសំរបសំរួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធរៀបចំទស្សនាទាន គំរោង ផែនការ និងកម្មវិធីការងារកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដាក់ជូនអង្គភាពសំរបសំរួលអចិន្ត្រៃយ៍ ពិនិត្យពិភាក្សា ដាក់ជូនក្រុមប្រឹក្សាកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ពិនិត្យ និងសំរេច

-សំរបសំរួល និងធ្វើទំនាក់ទំនងជាមួយក្រសួង ស្ថាប័នជាតិ និងអន្តរជាតិ ជំរុញនិងពង្រឹងការងារកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

-តាមដាន និងធ្វើរបាយការណ៍ បូកសរុបលទ្ធផល នៃការអនុវត្តគំរោងកម្មវិធីកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌នៅតាមបណ្តាក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធដាក់ជូន អ.ស.អ ពិនិត្យលើកយោបល់ជូន ក.ក.ច.យ

-រ៉ាប់រងការងារឯកសារទាំងអស់របស់ ក.ក.ច.យ និងរបស់ អ.ស.អព្រមទាំងឯកសារដទៃទៀតពាក់ព័ន្ធដល់ការងារកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

-រៀបចំការប្រជុំនានារបស់ ក.ក.ច.យ និងរបស់ អ.ស.អព្រមទាំងការប្រជុំផ្សេងៗទៀតទាក់ទងដល់ការងារកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

-បំពេញការងារផ្សេងៗទៀត ដែល អ.ស.អ និង ក.ក.ច.យប្រគល់ជូន ។

**មាត្រា ៣.-**

អង្គភាពគ្រប់គ្រងគំរោងកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដឹកនាំដោយនាយកអង្គភាពគ្រប់គ្រងគំរោង ០១រូប ថ្នាក់ស្មើ អគ្គនាយក និងមាននាយករងជាជំនួយការ ។

អង្គភាពគំរោង មានរចនាសម្ព័ន្ធ ដូចតទៅ :

១-ក្រុមគំរោងរដ្ឋបាល និងហិរញ្ញវត្ថុ

២-ក្រុមគំរោងកំណែទំរង់ច្បាប់

៣-ក្រុមគំរោងកំណែទំរង់ប្រព័ន្ធយុត្តិធម៌

៤-ក្រុមគំរោងការពារសិទ្ធិមនុស្ស និងមជ្ឈត្តកម្ម

៥-ក្រុមគំរោងប័ណ្ណសារ និងពត៌មានវិទ្យា ។

អង្គភាពគ្រប់គ្រងគំរោងកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ អាចពង្រីករចនាសម្ព័ន្ធរបស់ខ្លួនបានតាមការចាំបាច់ ។

**មាត្រា ៤.-**

ក្រុមគំរោងរដ្ឋបាល និងហិរញ្ញវត្ថុ មានភារកិច្ច :

-ជួយ អ.ស.អ ក្នុងការងារគ្រប់គ្រងរដ្ឋបាល និងហិរញ្ញវត្ថុរបស់គំរោងកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

-គ្រប់គ្រង និងចរាចរ លិខិត ឯកសាររដ្ឋបាលផ្សេងៗរបស់ អ.ស.អ និង ក.ក.ច.យ

-ធានាប្រសិទ្ធិភាព និងសុវត្ថិភាពរដ្ឋបាលរបស់អង្គភាពគំរោងកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

-បូកសរុប និងធ្វើរបាយការណ៍ ស្តីពីការងារកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

-គ្រប់គ្រងផ្នែករដ្ឋបាលនូវមន្ត្រីបុគ្គលិករបស់អង្គភាពគ្រប់គ្រងគំរោង

-បំពេញភារកិច្ចផ្សេងៗទៀត តាមការប្រគល់ជូនរបស់ អ.ស.អ និងក.ក.ច.យ ។

**មាត្រា ៥.-**

ក្រុមគំរោងកំណែទំរង់ច្បាប់ មានភារកិច្ចដូចតទៅ :

-សិក្សាស្រាវជ្រាវ លើកគំរោង កែលំអ ពង្រឹងសមត្ថភាពកសាងច្បាប់នៅតាមក្រសួង ស្ថាប័នរដ្ឋ

-សិក្សាស្រាវជ្រាវ រៀបចំនីតិវិធី នៃការតាក់តែងច្បាប់ និងលិខិតបទដ្ឋាននានា

-សិក្សាស្រាវជ្រាវរៀបចំសន្ទានុក្រម វចនានុក្រម វាក្យសព្ទ ពាក្យពេចន៍ និង ប្រជុំពាក្យផ្នែកច្បាប់

-លើកគំរោង និងធ្វើការអប់រំផ្សព្វផ្សាយច្បាប់

-បំពេញភារកិច្ចផ្សេងៗ តាមការប្រគល់ជូនរបស់ អ.ស.អ និង ក.ក.ច.យ ។

**មាត្រា ៦.-**

ក្រុមគំរោងកំណែទំរង់ប្រព័ន្ធយុត្តិធម៌ មានភារកិច្ចដូចតទៅ :

-សិក្សាស្រាវជ្រាវ លើកគំរោង កែលំអ ពង្រឹងសេវាយុត្តិធម៌អោយមានឯករាជ្យភាព តម្លាភាព ជំនឿទុកចិត្ត និងការទទួលខុសត្រូវខ្ពស់

-សិក្សាស្រាវជ្រាវ រៀបចំកម្មវិធីបង្កើនគុណភាពសេវាប្រព័ន្ធយុត្តិធម៌ ធ្វើអោយប្រសើរឡើងនូវការផ្តល់ជំនួយសេវាផ្នែកច្បាប់ ការអប់រំ និងបណ្តុះ បណ្តាលមេធាវី

-សិក្សាស្រាវជ្រាវ រៀបចំកម្មវិធីធ្វើអោយប្រសើរឡើងនូវប្រព័ន្ធសំរាប់អនុវត្តសេចក្តីសំរេចរបស់តុលាការ និងជំរុញអោយមានមូលដ្ឋានទិន្នន័យ នៃសេចក្តីរបស់តុលាការពីមុនៗមក

-បំពេញភារកិច្ចផ្សេងៗទៀត តាមការប្រគល់ជូនរបស់ អ.ស.អ និងក.ក.ច.យ ។

**មាត្រា ៧.-**

ក្រុមគំរោងការពារសិទ្ធិមនុស្ស និងវិជ្ជាត្តកម្ម មានភារកិច្ចដូចតទៅ:

-សិក្សាស្រាវជ្រាវ និងរៀបចំកម្មវិធីបង្កើតយន្តការ និងពង្រឹងការការពារសិទ្ធិជាមូលដ្ឋានរបស់ប្រជាពលរដ្ឋអោយកាន់តែប្រសើរឡើង

-សិក្សារៀបចំនីតិវិធី និងយន្តការដោះស្រាយជម្លោះជំនួសការកាត់ក្តីសាមញ្ញ

-បំពេញភារកិច្ចផ្សេងៗទៀត តាមការប្រគល់ជូនរបស់ អ.ស.អ និងក.ក.ច.យ ។

**មាត្រា ៨.-**

ក្រុមគំរោងឯកសារ និងពត៌មានវិទ្យា មានភារកិច្ចដូចតទៅ :

-ប្រមូល ចងក្រង ទុកដាក់ពត៌មាន និងឯកសារនានាពាក់ព័ន្ធដល់ការងារកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

-រៀបចំអត្ថបទ និងបោះពុម្ពផ្សាយ ព្រឹត្តិប័ត្ររបស់ អ.ស.អ និង ក.ក.ច.យ

-ផ្តល់សេវាពត៌មានវិទ្យាដល់គ្រប់ក្រុមគំរោងកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិ ធម៌

-កសាងមូលដ្ឋានទិន្នន័យច្បាប់ និងប្រមូលទិន្នន័យច្បាប់ទៅក្នុងប្រព័ន្ធពត៌មាន វិទ្យា

-បំពេញភារកិច្ចផ្សេងៗទៀត តាមការប្រគល់ជូនរបស់ អ.ស.អ និងក.ក.ច.យ ។

**មាត្រា ៩.-**

ក្រុមគំរោងនីមួយៗ ដឹកនាំដោយប្រធានក្រុមគំរោង ០១រូប ថ្នាក់ស្មើប្រធាននាយកដ្ឋាន និងមានអនុប្រធានជាជំនួយការ ។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់គំរោងនីមួយៗ ត្រូវកំណត់ដោយសេចក្តីសំរេច របស់ប្រធាន អ.ស.អ ។

**មាត្រា ១០.-**

មន្ត្រីដែលបំរើការនៅក្នុងអង្គភាពគ្រប់គ្រងគំរោងកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ជាមន្ត្រីនៃមុខងារសាធារណៈ និងអាចជ្រើសរើសជាប់កិច្ចសន្យាតាមការចាំបាច់ ព្រមទាំងអាចទទួលនូវប្រាក់ឧត្តម្ភផ្សេងៗ ដែលបានផ្តល់ពីប្រទេស ឬអង្គការផ្តល់ជំនួយអន្តរជាតិនានា ។

**មាត្រា ១១.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១២.-**

ទេសរដ្ឋមន្ត្រីរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន

សម្តេចនាយករដ្ឋមន្ត្រី សូមចុះហត្ថលេខា

**សហប្រធានក្រុមប្រឹក្សាកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌**

**ឱក មន្ទី** **សុខ អាន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចមាត្រា ១២

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ